- លោកឧត្តមសេនីយ៍ត្រី **ឡាយ ម៉ុនសុខ** នាយក នាយកដ្ឋានទាក់ទងអន្តរជាតិក្រសួងការពារជាតិ សមាជិកអចិន្ត្រៃយ៍
- លោកស្រី **យូ អយ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ឯក **ម៉ី រដ្ឋា** នាយរងខុទ្ទកាល័យអគ្គសេនាធិការ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ទោ **ឈួន ចំនួនឈាយ៉ា** នាយការិយាល័យជំនួយបរទេស នាយកដ្ឋានទាក់ទងអន្តរជាតិក្រសួងការពារជាតិ សមាជិកអចិន្ត្រៃយ៍
- លោកវរសេនីយ៍ទោ **ពត សុខ** នាយរងក្រុមផែនការ អគ្គសេនាធិការ សមាជិកអចិន្ត្រៃយ៍
- លោក **សយ សុខា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

ᘛ៚ᘚ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៩ អនក្រ.បក**

**ស្តីពីការបំពេញបន្ថែមតំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ជាសមាជិកគណៈកម្មាធិការជាតិគាំពារសំរាប់អភិវឌ្ឍន៍ជនបទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ

www.pheakdeylaw.com

១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យក្រោសបង្គាប់អោយកែសំរួលសមាសភាពរាជរដ្ឋាភិបាល លេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបាន ប្រកាស អោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- យោងអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈ កម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការ ដ្ឋានកិច្ចការនារី

**សំរេច**

**មាត្រា១** : បំពេញបន្ថែមជាសមាជិកនូវតំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្នុងគណៈកម្មការ ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទដែលបានចែងអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា២** : គណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ«គ ជ ទាន» និងគ្រប់ក្រសួងស្ថាប័ន នានា ដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

❀❀❀

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៦៩ អនក្រ តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

www.pheakdeylaw.com